**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ ០០៦៤/២៣ ន.គ.ស/សរ.ស.

ថ្ងៃសុក្រ ៣កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៣

# សេចក្តីជូនដំណឹង

## ស្តីពី

## ការពន្យារពេលអនុវត្តស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា លេខ ១៧ "កិច្ចសន្យាធានារ៉ាប់រង" និង លេខ ៩ "ឧបករណ៍ហិរញ្ញវត្ថុ" សម្រាប់ក្រុមហ៊ុនធានារ៉ាប់រង

អនុលោមតាមប្រកាសលេខ ០៦៨ សហវ.ប្រក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៩ ស្តីពីការដាក់ឱ្យប្រើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុកម្ពុជា, សេចក្តីជូនដំណឹងលេខ ០៩៧/០៩ សហវ-ក.ជ.គ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៩ ស្តីពីការដាក់ឱ្យប្រើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (CIFRS) និងស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម (CIFRS for SMEs) និងតាមសំណើរបស់សមាគមធានារ៉ាប់រងកម្ពុជា, និយ័តករគណនេយ្យនិងសវនកម្ម(**ន.គ.ស.**) នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ សូមជម្រាបជូនដំណឹងដល់ **លោក/លោកស្រី** ប្រធានក្រុមហ៊ុនធានារ៉ាប់រងទាំងអស់ដែលកំពុងធ្វើប្រតិបត្តិការផ្តល់សេវាធានារ៉ាប់រងគ្រប់ប្រភេទ ឱ្យបានជ្រាបដូចខាងក្រោម÷

១. និយ័តករគណនេយ្យនិងសវនកម្ម សម្រេច ពន្យារពេលអនុវត្តស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា លេខ ១៧ (CIFRS 17) *"កិច្ចសន្យាធានារ៉ាប់រង"* និង លេខ ៩ (CIFRS 9) *"ឧបករណ៍ហិរញ្ញវត្ថុ"* សម្រាប់ក្រុមហ៊ុនធានារ៉ាប់រងនៅកម្ពុជា រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤។ ក្រុមហ៊ុនធានារ៉ាប់រងដែលអាចអនុវត្តស្តង់ដាទាំងពីរនេះមុនពេលកំណត់ ត្រូវបានលើកទឹកចិត្ត។

២. ក្រុមហ៊ុនធានារ៉ាប់រងដែលទទួលយកការពន្យារពេលនេះ ត្រូវផ្តល់ជូននិយ័តករគណនេយ្យនិងសវនកម្មនូវឯកសារដូចខាងក្រោម÷

- ផែនការសកម្មភាពលម្អិតឆ្ពោះទៅការអនុវត្តស្តង់ដា CIFRS 17 *"កិច្ចសន្យាធានារ៉ាប់រង"* និងស្តង់ដា CIFRS 9 *"ឧបករណ៍ហិរញ្ញវត្ថុ"* នៅដើមឆ្នាំ២០២៥ ឱ្យបានមុនដំណាច់ខែកញ្ញា ឆ្នាំ២០២៣។
- របាយការណ៍ប្រចាំត្រីមាសអំពីវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពលម្អិត និងត្រូវធ្វើបទបង្ហាញជូន **ន.គ.ស.** រៀងរាល់ ៦ (ប្រាំមួយ) ខែម្តង ដោយគិតចាប់ពីថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ តទៅ។

៣. ក្នុងអំឡុងពេលនៃការពន្យារ ក្រុមហ៊ុនធានារ៉ាប់រងត្រូវបន្តប្រើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (CIFRS) ដែលមានការពាក់ព័ន្ធជាធរមាន។

ការមិនគោរពតាមសេចក្តីជូនដំណឹងនេះ ត្រូវចាត់ទុកថាជាការល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

អាស្រ័យហេតុនេះ សូម **លោក/លោកស្រី** ប្រធានក្រុមហ៊ុនធានារ៉ាប់រងទាំងអស់ ជ្រាបជាព័ត៌មាន និងត្រូវអនុវត្តសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**អគ្គនាយក**

**ប៊ូ ថារិន**

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.
គេហទំព័រ : www.acar.gov.kh
អ៊ីម៉ែល : info@acar.gov.kh
ទូរស័ព្ទ ០៥៥ - ២៣ ៨៨២ ១១១
Phone: 023 882 111